ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ០១ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ទម្រង់គំរូសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ

## ១. សេចក្តីផ្តើម

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភា បានកំណត់ការអភិវឌ្ឍមូលធនមនុស្ស ជាអាទិភាពទី១ និងមុំទី១ បានលើកឡើងអំពី **"ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា"**។ ឈរលើមូលដ្ឋាននេះ ក្រសួងបានកំណត់នូវអាទិភាពចំនួនប្រាំបីៈ ១) ការពង្រឹងអភិបាលកិច្ចសាលារៀន ២) ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស ៣) ការលើកកម្ពស់សុខភាពសិក្សា ដោយយកចិត្តទុកដាក់លើសុខភាពសិស្សតាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន ៤) ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូ រដ្ឋ និងសហគមន៍ ដើម្បីការអប់រំ ៥) ការអប់រំឌីជីថល ៦) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា ៧) ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព និង ៨) ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

ក្រសួងបានបង្រួមខ្លឹមសារគោលនយោបាយអប់រំឱ្យនៅតែមួយគឺ "ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត" ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ បន្តផ្តោតលើការធ្វើកំណែទម្រង់អប់រំនៅគ្រប់កម្រិត និងគ្រប់ផ្នែក ជាពិសេសកំណែទម្រង់សាលារៀនឆ្ពោះទៅសម្រេចស្តង់ដាសាលារៀនគំរូ និងកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំ**គោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(ម.ដ.ស)** (Public School Operating Fund Management Guideline - SOF) ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងបង្កលក្ខណៈងាយស្រួល និងភាពទន់ភ្លន់ក្នុងការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ។ គោលការណ៍នេះ ទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈលិខិតលេខ ១០០៤៣ សហវ.អថ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ដែលអនុញ្ញាតឱ្យប្រើប្រាស់គោលការណ៍ណែនាំនេះចាប់តាំងពីឆ្នាំ២០១៩។ គោលការណ៍ណែនាំ ម.ដ.ស និងការគ្រប់គ្រងតាមសាលារៀន ជំរុញលើកទឹកចិត្តឱ្យគណៈគ្រប់គ្រងសាលារៀន ឬគណៈកម្មការគ្រប់គ្រងសាលារៀន មានបំណិនក្នុងការកៀរគរធនធានពីគ្រប់ប្រភព ដោយបង្កើនការចូលរួម និងភាពជឿទុកចិត្តពីគ្រប់ភាគីអ្នកពាក់ព័ន្ធ សម្រាប់


អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh

ការអនុវត្តសកម្មភាពនៅកម្រិតសាលារៀន ជាពិសេសសាលារៀនត្រូវធ្វើស្វ័យវាយតម្លៃ ដើម្បីពិនិត្យលើវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តសកម្មភាព ដែលជាមូលដ្ឋានសម្រាប់ធ្វើការកែលម្អចំណុចខ្វះខាតតាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងការអនុវត្តថវិកា ព្រមទាំងការពិនិត្យតាមដាន និងវាយតម្លៃសាលារៀនតាមឆ្នាំសិក្សានីមួយៗ ជាពិសេសផ្តោតសំខាន់លើលទ្ធផលនៃការសិក្សារបស់សិស្សានុសិស្ស។

ក្នុងន័យនេះ គ្រឹះស្ថានសិក្សាសាធារណៈ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងការអនុវត្តថវិកា ឱ្យឆ្លើយតបនឹងតម្រូវការអាទិភាពជាក់ស្តែង ស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំក្នុងការផ្តល់សេវាអប់រំ និងជួយឱ្យកុមារគ្រប់រូបមានលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត។

## ២. វត្ថុបំណង

វត្ថុបំណងនៃសេចក្តីណែនាំរួមមាន៖

- ផ្តល់ការណែនាំផ្នែកបច្ចេកទេសក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ក្នុងការកែលម្អសាលារៀនឱ្យឆ្លើយតបទៅនឹងការសម្រេចអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា
- កំណត់ទម្រង់គំរូប្រើប្រាស់មានស្តង់ដាររួម និងមានសង្គតិភាពជាមួយលិខិតបទដ្ឋានគតិយុត្តជាធរមានក្នុងការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ សម្រាប់អនុវត្តនៅសាលារៀនសាធារណៈ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត
- ផ្តល់ក្របខ័ណ្ឌសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃជាប្រចាំ រួមគ្នារវាងសាលារៀន និងភាគីពាក់ព័ន្ធ។

## ៣. យន្តការនៃការរៀបចំផែនការថវិកាសាលារៀន

ការរៀបចំផែនការថវិកា(ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ) របស់សាលារៀន ត្រូវឆ្លើយតបនឹងស្តង់ដាសាលារៀនគំរូ និងសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន។ ការរៀបចំផែនការថវិកាសាលារៀន ត្រូវដឹកនាំដោយនាយក/នាយិកាសាលារៀន និងថ្នាក់ដឹកនាំគណៈកម្មការគ្រប់គ្រងសាលារៀន ដោយមានការចូលរួមពីសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន អាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំសង្កាត់ មេឃុំ/ចៅសង្កាត់ ប្រធានភូមិ ប្រធានក្រុមក្រុមប្រឹក្សាយុវជននិងកុមារ តំណាងសិស្សានុសិស្ស មាតាបិតាសិស្ស អ្នកអាណាព្យាបាល អង្គការដៃគូអភិវឌ្ឍន៍ ស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីសហការពិភាក្សារួមគ្នាលើតម្រូវការចាំបាច់របស់សាលារៀន និងសហគមន៍លើបញ្ហាប្រឈមចម្បងៗ និងលទ្ធផលសិក្សារបស់សិស្សឱ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់ ជាពិសេសកុមារបានចូលរៀនគ្រប់គ្នា សិស្សរៀនចេះ ប្រឡងជាប់ និងបន្តរៀនចប់តាមកម្រិតសិក្សានីមួយៗ។

### ៣.១ ផែនការយុទ្ធសាស្ត្រថវិកា

#### ៣.១.១ និយមន័យ និងគោលបំណង

ផែនការយុទ្ធសាស្ត្រថវិកា គឺជាផែនការថវិការយៈពេលមធ្យម(៣ឆ្នាំរំកិល) ដែលឆ្លុះបញ្ចាំងពីគោលបំណងគោលនយោបាយ ការកសាងផែនការយុទ្ធសាស្ត្រអាទិភាព ដើម្បីអនុវត្តនិងកំណត់សូចនាករនិងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្ត។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល (២)-បង្កើនវិចារណកម្មអាទិភាពចំណាយរបស់ក្រសួង ស្ថាប័ន (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង ស្ថាប័ន (៤)-ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់ការងារអាទិភាព និង(៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។

#### ៣.១.២ ក្របខ័ណ្ឌពេលវេលានៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

- ❑ ផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំរំកិល) ត្រូវរៀបចំជារៀងរាល់ឆ្នាំ
- ❑ ក្របខ័ណ្ឌពេលវេលានៃការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់សាលារៀន ត្រូវស្របតាមគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) និងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

#### ៣.១.៣ ទម្រង់គំរូផែនការយុទ្ធសាស្ត្រថវិកា

ទម្រង់គំរូផែនការយុទ្ធសាស្ត្រថវិការបស់សាលារៀន មានដូចភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ។

### ៣.២ ផែនការថវិកាប្រចាំឆ្នាំ

#### ៣.២.១ និយមន័យ និងគោលបំណង

ផែនការថវិកាប្រចាំឆ្នាំ គឺជាការរៀបចំផែនការចំណូល-ចំណាយរបស់អង្គភាពណាមួយ (សាកលវិទ្យាល័យ វិទ្យាស្ថាន នាយកដ្ឋាន សាលារៀន ឬស្ថាប័នផ្សេងៗ) សម្រាប់រយៈពេលមួយឆ្នាំ ដោយធានាការប្រើប្រាស់ធនធានហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព និងស្របតាមគោលដៅអភិវឌ្ឍន៍របស់អង្គភាព។

ផែនការថវិកាប្រចាំឆ្នាំ គឺមានគោលបំណងសំខាន់ៗដូចជា៖ (១)-កំណត់ទិសដៅនៃការចំណាយ និងប្រើប្រាស់ធនធាន (២)-ធានាបាននូវប្រសិទ្ធផល និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកា (៣)-ផ្តល់ភាពច្បាស់លាស់ និងគណនេយ្យភាព (៤)-ជួយក្នុងការបង្កើតវិន័យហិរញ្ញវត្ថុ (៥)-រៀបចំការស្នើសុំថវិកា និង(៦)-ជាជំហានចម្បងសម្រាប់ការតាមដាន និងវាយតម្លៃ។

#### ៣.២.២ ក្របខ័ណ្ឌពេលវេលានៃការរៀបចំផែនការថវិកាប្រចាំឆ្នាំ

- ❑ ផែនការថវិកាប្រចាំឆ្នាំ ត្រូវរៀបចំជារៀងរាល់ឆ្នាំ
- ❑ ក្របខ័ណ្ឌពេលវេលានៃការរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់សាលារៀន ត្រូវស្របតាមគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) និងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

#### ៣.២.៣ ទម្រង់គំរូផែនការថវិកាប្រចាំឆ្នាំ

ទម្រង់គំរូផែនការថវិការបស់សាលារៀន មានដូចភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី២ នៃសេចក្តីណែនាំនេះ។

### ៣.៣ ផែនការប្រតិបត្តិប្រចាំឆ្នាំ

#### ៣.៣.១ និយមន័យ និងគោលបំណង

ផែនការប្រតិបត្តិប្រចាំឆ្នាំ គឺជាផែនការរយៈពេលខ្លី(១ឆ្នាំ) ដែលត្រូវបានរៀបចំឡើងដើម្បីប្រែក្លាយអាទិភាពអប់រំ យុវជន និងកីឡាក្នុងឆ្នាំទៅជាសកម្មភាពប្រតិបត្តិ ស្របតាមទិសដៅសន្និបាតអប់រំប្រចាំឆ្នាំថ្នាក់ជាតិ រាជធានី ខេត្ត ផែនការយុទ្ធសាស្ត្រថវិកាសាលារៀន និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន។

ផែនការប្រតិបត្តិប្រចាំឆ្នាំ គឺមានសារៈប្រយោជន៍សម្រាប់៖ (១)-ជាឯកសារបង្អែកផ្លូវការមួយ ដែលសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន សហគមន៍ ដៃគូអភិវឌ្ឍន៍ និងគ្រប់អ្នកពាក់ព័ន្ធ ប្រើប្រាស់រួមគ្នា ដើម្បីឈានទៅសម្រេចវត្ថុបំណងរួមគឺ ការផ្តល់សេវាអប់រំឱ្យមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាដល់កុមារកម្ពុជាគ្រប់រូប ព្រមទាំងលទ្ធផលសិក្សារបស់សិស្សមានគុណភាព និងប្រសិទ្ធភាពខ្ពស់ ជាពិសេសកុមារបានចូលរៀនគ្រប់រូប សិស្សរៀនចេះ ប្រឡងជាប់ និងបន្តរៀនចប់តាមកម្រិតសិក្សានីមួយៗ (២)-បង្ហាញពីសកម្មភាពលម្អិតតាមអនុវិស័យ (ការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សា និងការអប់រំបច្ចេកទេស) កម្មវិធី និងអនុកម្មវិធី ដែលនឹងត្រូវអនុវត្តដោយសាលារៀន សហគមន៍ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល (៣)-បង្ហាញអំពីទំនាក់ទំនងរវាងសកម្មភាព លទ្ធផលគ្រោងទុក ចំណុចដៅប្រចាំឆ្នាំ ប្រភពថវិកា អ្នកទទួលបន្ទុក និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់សម្រាប់ការអនុវត្តឆ្លើយតបនឹងសូចនាករស្តង់ដាសាលារៀនគំរូ។

#### ៣.៣.២ ក្របខ័ណ្ឌពេលវេលានៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ

- ❑ ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ត្រូវរៀបចំជារៀងរាល់ឆ្នាំ
- ❑ ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននេះ នឹងត្រូវគណៈកម្មការគ្រប់គ្រងសាលារៀន យកទៅដាក់ជាធាតុចូលនៅក្នុងផែនការវិនិយោគរបស់ឃុំ សង្កាត់ ដើម្បីកៀរគរថវិកាពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។

ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ(N+1) របស់សាលារៀន ត្រូវអនុវត្តទៅតាមកាលបរិច្ឆេទកំណត់ដូចខាងក្រោម៖

| កាលបរិច្ឆេទ | សកម្មភាព |
|---|---|
| សប្តាហ៍ទី៤<br>ខែកញ្ញា (ឆ្នាំ N) | សាលារៀនប្រជុំរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ(N+1) ជាមួយគ្រប់ភាគីពាក់ព័ន្ធ |
| សប្តាហ៍ទី១<br>ខែតុលា (ឆ្នាំ N) | សេចក្តីព្រាងផែនការប្រតិបត្តិប្រចាំឆ្នាំ(N+1) និងផ្តល់យោបល់បន្ថែមពីអ្នកពាក់ព័ន្ធ |
| សប្តាហ៍ទី២<br>ខែតុលា (ឆ្នាំ N) | សេចក្តីព្រាងចុងក្រោយផែនការប្រតិបត្តិប្រចាំឆ្នាំ(N+1) និងផ្តល់យោបល់បន្ថែមពីអ្នកពាក់ព័ន្ធ |
| សប្តាហ៍ទី៣<br>ខែតុលា (ឆ្នាំ N) | បញ្ចប់ផែនការប្រតិបត្តិប្រចាំឆ្នាំ(N+1) របស់សាលារៀន |

### ៣.៣.៣ ទម្រង់គំរូផែនការប្រតិបត្តិប្រចាំឆ្នាំ

ទម្រង់គំរូផែនការប្រតិបត្តិប្រចាំឆ្នាំ មានដូចភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី៣ នៃសេចក្តីណែនាំនេះ។

## ៤. ទម្រង់គំរូកិច្ចបញ្ជិកាគណនេយ្យនិងរបាយការណ៍សម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យប្រើប្រាស់សៀវភៅគោលការណ៍ណែនាំស្តីពី**ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ** ចាប់តាំងពីឆ្នាំ២០១៩ មកម្ល៉េះ។ គោលការណ៍ណែនាំនេះ មានទម្រង់គំរូមួយចំនួនមានទិន្នន័យលម្អិតច្រើននៅលើជួរឈរ ធ្វើឱ្យតារាងមានភាពតូចចង្អៀតពិបាករៀបចំ និងបោះពុម្ពរក្សាទុកទិន្នន័យ ព្រមទាំងមិនគ្របដណ្តប់លើទិន្នន័យឥណទានកែតម្រូវ។ ម្យ៉ាងទៀត ចាប់ពីឆ្នាំ២០២៥ តទៅ គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា ដែលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តកិច្ចបញ្ជិកាគណនេយ្យតាមទម្រង់គំរូនៃសារាចរលេខ ០០២ សហវ.ស.រ.អរតន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ ដែលធ្វើឱ្យទម្រង់គំរូមួយចំនួនមិនមានសង្គតិភាពគ្នា រវាងសាលារៀនដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ជាតិ។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(SOF) តាមរយៈលិខិតលេខ ២៤១១ អយក.ហវ ស្តីពី ***ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(SOF)*** និងសារាចរលេខ ០០២ សហវ.ស.រ.អរតន ស្តីពីកិច្ចបញ្ជិកាគណនេយ្យលើការគ្រប់គ្រង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅផ្នែកទី២ នីតិវិធី និងកិច្ចបញ្ជិកាគណនេយ្យសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូចនៅគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងការអប់រំបឋមសិក្សានៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រង់ចំណុចទី២.៣.៩ កិច្ចបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ *ត្រូវប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ*។ ក្នុងន័យនេះ សាលារៀនសាធារណៈ ត្រូវប្រើប្រាស់**ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) មុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ** ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុសាលារៀនសាធារណៈពីគ្រប់ប្រភពថវិកាឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយការកត់ត្រារាល់ប្រតិបត្តិការហិរញ្ញវត្ថុ ប្រព័ន្ធនឹងរៀបចំជាស្វ័យប្រវត្តិនូវកិច្ចបញ្ជិកាគណនេយ្យហិរញ្ញកិច្ច កិច្ចបញ្ជិកាគណនេយ្យសម្ភារៈ របាយការណ៍ចំណាយថវិកា និងរបាយការណ៍ផ្សេងៗទៀត។

ក្នុងគោលបំណងកំណត់ទម្រង់គំរូមានស្តង់ដារូម និងមានសង្គតិភាពជាមួយលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ក្រសួងបានកំណត់ទម្រង់គំរូកិច្ចបញ្ជិកាគណនេយ្យហិរញ្ញកិច្ច ទម្រង់គំរូកិច្ចបញ្ជិកាគណនេយ្យសម្ភារៈ និងទម្រង់គំរូរបាយការណ៍សម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈសម្រាប់សាលារៀននៅថ្នាក់ជាតិ សាលារៀនផ្ទេរទៅថ្នាក់ក្រោមជាតិ ការិយាល័យអប់រំ

យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត មានដូចភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី៤ ទី៥ ទី៦ និងទី៧ នៃសេចក្ដីណែនាំនេះ។

**៥. យន្តការពិនិត្យតាមដាន និងវាយតម្លៃផែនការសាលារៀន**

ដើម្បីពិនិត្យតាមដាន និងវាយតម្លៃផែនការថវិកាសាលារៀនប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពសាលារៀនត្រូវ៖

- បង្កើតក្រុមការងារពិនិត្យតាមដាន និងវាយតម្លៃផែនការថវិកាសាលារៀន
- ពិនិត្យលើវឌ្ឍនភាពដែលសម្រេចបាន និងទិសដៅបន្តរបស់សាលារៀនដែលបានកំណត់
- កំណត់អំពីមេរៀនពិសោធន៍ ដែលទទួលបានពីការអនុវត្តកន្លងមក
- កំណត់បញ្ហានានា សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការសាលារៀនឆ្នាំបន្ទាប់
- ពិនិត្យតាមដាន និងវាយតម្លៃគ្រប់កម្មវិធី និងសកម្មភាពទាំងអស់
- កំណត់កាលបរិច្ឆេទ និងការផ្សព្វផ្សាយលទ្ធផល នៃការពិនិត្យតាមដាន និងវាយតម្លៃ
- ទទួលមតិយោបល់ពីអ្នកពាក់ព័ន្ធ លើការអនុវត្តផែនការសាលារៀន ដើម្បីកែលម្អផែនការនៅពេលបន្ទាប់។

ក្រសួងសង្ឃឹមថា មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយសេចក្ដីណែនាំនេះឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ត្រូវបន្តផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់សាលារៀនសាធារណៈ។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀនសាធារណៈ ត្រូវអនុវត្តតាមសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីឆ្នាំ២០២៦ តទៅ។

ថ្ងៃអង្គារ ៧រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**ឧបសម្ព័ន្ធភ្ជាប់លិខិតលេខ ១១ អយក.សណាន ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២៦**
**ស្តីពី ទម្រង់គំរូសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ**

**ឧបសម្ព័ន្ធទី១៖ ទម្រង់គំរូផែនការយុទ្ធសាស្ត្រថវិកា**

## ១. សេចក្តីផ្តើម

សេចក្តីផ្តើម ត្រូវបង្ហាញយ៉ាងច្បាស់អំពីបរិបទ និងគោលបំណងនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ព្រមទាំងបញ្ជាក់ពីរបៀប និងគោលបំណងនៃការប្រើប្រាស់ផែនការនេះ ក្នុងការគាំទ្រការរៀបចំផែនការ ការសម្រេចចិត្ត និងការពិនិត្យតាមដានការអនុវត្តថវិកា។ សេចក្តីផ្តើម មិនផ្តោតលើព័ត៌មានបច្ចេកទេស ឬសេចក្តីលម្អិតនោះទេ ប៉ុន្តែផ្តោតលើការបង្ហាញទិសដៅទូទៅ និងសារៈសំខាន់នៃការរៀបចំផែនការនេះ។ សេចក្តីផ្តើម ត្រូវផ្តោតសំខាន់លើ **"ផលប្រយោជន៍ជូនសិស្សានុសិស្ស"** និង **"ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការប្រើប្រាស់ថវិកា"** ដោយសាលារៀនត្រូវតែបង្ហាញថា រាល់"**រៀល**"នៃចំណាយ គឺដើម្បីលើកកម្ពស់គុណភាពអប់រំ។ ក្នុងន័យនេះ សេចក្តីផ្តើម ត្រូវផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ការរំលេចអំពីទស្សនវិស័យ បេសកកម្ម និងការកិច្ចចម្បងៗសម្រាប់ឆ្នាំ(N+1)ដល់ឆ្នាំ(N+3) ក្នុងក្របខ័ណ្ឌនៃតួនាទី និងភារកិច្ចរបស់សាលារៀន
- គោលបំណងនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយត្រូវផ្សារភ្ជាប់ជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងអាទិភាពកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា
- គោលការណ៍ប្រើប្រាស់ធនធានហិរញ្ញវត្ថុ(គូសបញ្ជាក់ពីគោលការណ៍ដូចជា តម្លាភាព សមធម៌ បរិយាបន្ន ប្រសិទ្ធភាព ការទទួលខុសត្រូវ និងនិរន្តរភាព)
- ការចូលរួមពីភាគីពាក់ព័ន្ធ និងការប្តេជ្ញាចិត្ត
- វិសាលភាព និងក្របខណ្ឌពេលវេលា

## ២. វឌ្ឍនភាព និងបញ្ហាប្រឈម

### ២.១ វឌ្ឍនភាព

ក្នុងឆ្នាំសិក្សា........ សាលារៀនសម្រេចបានសូចនាករគន្លឹះ/គោលសំខាន់ៗ ដែលមានវឌ្ឍនភាពល្អប្រសើរ ដូចខាងក្រោម៖

#### ២.១.១ លទ្ធផលសិក្សារបស់សិស្ស

- បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី១ ស្តីពីលទ្ធផលសិក្សារបស់សិស្ស សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

#### ២.១.២ ការបង្រៀននិងរៀន

- បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី២ ស្តីពី ការបង្រៀន និងរៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ

- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

### ២.១.៣ ការចូលរួមរបស់សហគមន៍

- បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៣ ស្តីពីការចូលរួមរបស់សហគមន៍ សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

### ២.១.៤ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន

- បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៤ ស្តីពីដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

### ២.១.៥ គណនេយ្យភាពរបស់សាលារៀន

- បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៥ ស្តីពីគណនេយ្យភាពរបស់សាលារៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

## ២.២ បញ្ហាប្រឈម

ទោះបីជាសាលារៀនមានវឌ្ឍនភាពដូចបានរៀបរាប់ខាងលើ ក៏សាលារៀនមានបញ្ហាប្រឈមមិនអាចសម្រេចបានសូចនាករគន្លឹះ/គោលសំខាន់ៗ ដូចខាងក្រោម៖

### ២.២.១ លទ្ធផលសិក្សារបស់សិស្ស

- បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី១ ស្តីពីលទ្ធផលសិក្សារបស់សិស្ស សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

### ២.២.២ ការបង្រៀននិងរៀន

- បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី២ ស្តីពីការបង្រៀននិងរៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម

- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

### ២.២.៣ ការចូលរួមរបស់សហគមន៍

- បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្រ្តថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៣ ស្តីពីការចូលរួមរបស់សហគមន៍ សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

### ២.២.៤ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន

- បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្រ្តថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៤ ស្តីពីដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

### ២.២.៥ គណនេយ្យភាពរបស់សាលារៀន

- បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N-1) ធៀបនឹងគោលដៅឆ្នាំ(N-1) ដែលសាលារៀនបានកំណត់ក្នុងផែនការយុទ្ធសាស្រ្តថវិកាឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៥ ស្តីពីគណនេយ្យភាពរបស់សាលារៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

## ៣. សូចនាករសមិទ្ធកម្ម និងគោលដៅ

- សាលារៀន ត្រូវកំណត់សូចនាករសមិទ្ធកម្មនិងគោលដៅ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនិងសមិទ្ធផលនៃការអនុវត្តសកម្មភាពនីមួយៗ
- សូមសរសេរអំពី សូចនាករសមិទ្ធកម្មនិងគោលដៅ ឱ្យមានសង្គតិភាពនឹងផែនការយុទ្ធសាស្រ្តវិស័យអប់រំរាជធានីខេត្ត និងក្រុង ស្រុក ខណ្ឌ ឬសន្និបាតអប់រំប្រចាំឆ្នាំថ្នាក់រាជធានី ខេត្ត ពិសេសសាលារៀនត្រូវកំណត់គោលដៅឱ្យឆ្លើយតបនឹងស្តង់ដាសាលារៀនគំរូ
- ខ្លឹមសារសូចនាករនៃស្តង់ដាសាលារៀនគំរូ មានដូចក្នុងឯកសារស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ស្តង់ដាសាលាបឋមសិក្សាគំរូ និងស្តង់ដាសាលាមធ្យមសិក្សាគំរូ

**តារាងទី១៖ សូចនាករសមិទ្ធកម្ម និងគោលដៅ**

| ស្តង់ដានិងសូចនាករ | ឆ្នាំគ្រោងថវិកា (N+1) (រៀល) | លទ្ធផលសូចនាករឆ្នាំមុន (N-1) | គោលដៅសូចនាករ | | | | |
|---|---|---|---|---|---|---|---|
| | | | ឆ្នាំបច្ចុប្បន្ន ( N) | ឆ្នាំគ្រោងថវិកា (N+1) | | ឆ្នាំគ្រោងថវិកា (N+2) | ឆ្នាំគ្រោងថវិកា (N+3) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ (N)) | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស** | | | | | | | |
| ១. ការប្រមូលកុមារចូលរៀន | | | | | | | |
| ១.១ ............................. | | | | | | | |
| ..................................... | | | | | | | |
| **ស្តង់ដាទី២៖ ការបង្រៀននិងរៀន** | | | | | | | |
| ១. ការអនុវត្តវិធីសាស្ត្របង្រៀន | | | | | | | |
| ១.១ ............................. | | | | | | | |
| ..................................... | | | | | | | |
| **ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍** | | | | | | | |
| ១. ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងថ្នាក់រៀន... | | | | | | | |
| ១.១ ............................. | | | | | | | |
| ..................................... | | | | | | | |
| **ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន** | | | | | | | |
| ១. ការគ្រប់គ្រងរដ្ឋបាលទូទៅ | | | | | | | |
| ១.១ ............................. | | | | | | | |
| ..................................... | | | | | | | |
| **ស្តង់ដាទី៥៖ គណនេយ្យភាព** | | | | | | | |
| ១. វេទិកាសាធារណៈ | | | | | | | |
| ១.១............................. | | | | | | | |
| ..................................... | | | | | | | |

## ៤. តម្រូវការថវិកា

ជាគោលការណ៍ ការកំណត់តម្រូវការថវិកា ឬតម្រូវការចំណាយ ត្រូវគិតគូរលើទិដ្ឋភាពបី៖ ទី១) ផែនការសកម្មភាព ឬសកម្មភាពការងារដែលត្រូវបន្តអនុវត្ត ទី២) ផែនការសកម្មភាព ឬសកម្មភាពដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ និងទី៣) ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី។ ហេតុនេះ រាល់ការកំណត់តម្រូវការចំណាយដែលធំ និងខ្ពស់ជាងគោលការណ៍ ដែលចែងក្នុងសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា(ផ្នែកការគ្រោងចំណាយ) គឺត្រូវផ្តល់ការពន្យល់ និងផ្តល់អំណះអំណាងឱ្យបានត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់។

## តារាងទី២៖ ការកំណត់តម្រូវការចំណាយ

| ល.រ | សកម្មភាព | ច្បាប់ហិរញ្ញវត្ថុឆ្នាំ N | | | | | គ្រោងតម្រូវការផែណទានសម្រាប់ឆ្នាំ N+1 | | | | | គ្រោងតម្រូវការផែណទានសម្រាប់ឆ្នាំ N+2 | | | | | គ្រោងតម្រូវការផែណទានសម្រាប់ឆ្នាំ N+3 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ថវិកា រដ្ឋ | ថវិកា ដៃគូ | ថវិកា សហគមន៍ | ថវិកា ផ្សេងៗ | សរុប | ថវិកា រដ្ឋ | ថវិកា ដៃគូ | ថវិកា សហគមន៍ | ថវិកា ផ្សេងៗ | សរុប | ថវិកា រដ្ឋ | ថវិកា ដៃគូ | ថវិកា សហគមន៍ | ថវិកា ផ្សេងៗ | សរុប | ថវិកា រដ្ឋ | ថវិកា ដៃគូ | ថវិកា សហគមន៍ | ថវិកា ផ្សេងៗ |
| រូបមន្ត | | 1=2+3+4+5 | 2 | 3 | 4 | 5 | 6=7+8+9+10 | 7 | 8 | 9 | 10 | 11=12+13+14+15 | 12 | 13 | 14 | 15 | 16=17+18+19+20 | 17 | 18 | 19 | 20 |
| សរុបរួម | | | | | | | | | | | | | | | | | | | | | |
| ១ | គាំទ្រកិច្ចដំណើរការ | | | | | | | | | | | | | | | | | | | | |
| ១.១ | កិច្ចដំណើរការរដ្ឋបាល | | | | | | | | | | | | | | | | | | | | |
| ១.២ | ការថែទាំនិងជួសជុលផ្សេងៗ | | | | | | | | | | | | | | | | | | | | |
| ២ | កែលម្អគុណភាពអប់រំ | | | | | | | | | | | | | | | | | | | | |
| ២.១ | ការចូលរៀនដោយសមធម៌ និងបង្ការសិស្សបោះបង់ | | | | | | | | | | | | | | | | | | | | |
| ២.២ | សម្ភារៈរៀន និងបង្រៀន | | | | | | | | | | | | | | | | | | | | |
| ២.៣ | ការកែលម្អបរិស្ថាន និងទីធ្លាកម្សាន្ត | | | | | | | | | | | | | | | | | | | | |
| ២.៤ | អប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | | | | | | | | | | | | | | | |

### ៥. សេចក្តីសន្និដ្ឋាន

ការសន្និដ្ឋានរួម ដោយធ្វើការបូកសរុបសង្ខេបអំពីសារៈសំខាន់នៃផែនការយុទ្ធសាស្ត្រថវិកាដែលបានរៀបចំ ព្រមជាមួយនឹងការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានដាក់ចេញ។

ថ្ងៃ.............................. ខែ.................... ឆ្នាំ................. ព.ស........

.............................. ថ្ងៃទី........ខែ................ ឆ្នាំ................

**ប្រធានគ.ម.ស**

**បានពិនិត្យត្រឹមត្រូវ**

**ប្រធានគ.គ.ស**

**បានពិនិត្យត្រឹមត្រូវ**

**ប្រធានការិយាល័យអប់រំ យុវជន និងកីឡា**

**បានឃើញនិងឯកភាព**

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡា**

**ឬ ¹**

**²អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**

សម្គាល់៖

១) គ្រឹះស្ថានសិក្សាសាធារណៈស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវអនុម័ត(បានឃើញនិងឯកភាព)ដោយលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

២) គ្រឹះស្ថានសិក្សាសាធារណៈត្រូវបានផ្ទេរទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុម័ត(បានឃើញនិងឯកភាព)ដោយលោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

## ឧបសម្ព័ន្ធភ្ជាប់លិខិតលេខ១១ អយក.សណានចុះថ្ងៃទី១០ ខែ មិនា ឆ្នាំ២០២៦

## ស្តីពី ទម្រង់គំរូសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ

### ឧបសម្ព័ន្ធទី២៖ ទម្រង់គំរូផែនការថវិកាប្រចាំឆ្នាំ

### ឧបសម្ព័ន្ធទី២.១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ...** *ទម្រង់គំរូលេខ ១.១ក*

**ឈ្មោះសាលារៀន...........**

**ផែនការថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាសម្រាប់មូលនិធិដំណើរការសាលារៀនសាធារណៈឆ្នាំ...**

កម្មវិធីទី......

អនុកម្មវិធីទី......

ចង្កោមសកម្មភាព......

សកម្មភាព..........

លេខកូដភូមិសាស្ត្រ..........

ឯកតា៖ រៀល

| ល.រ | បរិយាយ | ប្រភពថវិកា | សរុបរួម | | | | | លើកទី១ | | | | | លើកទី២ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | 60028 | 60058 | 61058 | 61108 | សរុប | 60028 | 60058 | 61058 | 61108 | សរុប | 60028 | 60058 | 61058 | 61108 |
| រូបមន្ត | | | 1=2+3+4+5 | 2=7+12 | 3=8+13 | 4=9+14 | 5=10+15 | 6=7+8+9+10 | 7 | 8 | 9 | 10 | 11=12+13+14+15 | 12 | 13 | 14 | 15 |
| I | សរុបរួម | សរុប | | | | | | | | | | | | | | | |
| | | រដ្ឋ | | | | | | | | | | | | | | | |
| | | ដៃគូ | | | | | | | | | | | | | | | |
| | | សហគមន៍ | | | | | | | | | | | | | | | |
| | | ផ្សេងៗ | | | | | | | | | | | | | | | |
| ក | កម្រិត.... | សរុប | | | | | | | | | | | | | | | |
| | | រដ្ឋ | | | | | | | | | | | | | | | |
| | | ដៃគូ | | | | | | | | | | | | | | | |
| | | សហគមន៍ | | | | | | | | | | | | | | | |
| | | ផ្សេងៗ | | | | | | | | | | | | | | | |
| ខ | កម្រិត.... | សរុប | | | | | | | | | | | | | | | |
| | | រដ្ឋ | | | | | | | | | | | | | | | |
| | | ដៃគូ | | | | | | | | | | | | | | | |
| | | សហគមន៍ | | | | | | | | | | | | | | | |
| | | ផ្សេងៗ | | | | | | | | | | | | | | | |

ថ្ងៃ.................. ខែ........ ឆ្នាំ........... ព.ស...

ធ្វើនៅ........ ថ្ងៃទី........ ខែ........ឆ្នាំ....

**បានឃើញនិងឯកភាព** **ហេរញ្ញិក**

**ប្រធានគ.ម.ស**

ឧបសម្ព័ន្ធទី២.២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ...** *ទម្រង់គំរូលេខ ១.១៥*

**ឈ្មោះសាលារៀន............**

**ផែនការថវិកាតាមសកម្មភាពសម្រាប់មូលនិធិដំណើរការសាលារៀនសាធារណៈឆ្នាំ...**

តំបន់៖...

ចំនួនសិស្សសរុប៖... ចំនួនសិស្សស្រីសរុប៖...

ឯកតា៖ រៀល

| ល.រ | បរិយាយ | សរុប | | | កម្រិត... | | | កម្រិត... | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | លើកទី១ | លើកទី២ | សរុប | លើកទី១ | លើកទី២ | សរុប | លើកទី១ | លើកទី២ |
| រូបមន្ត | | 1=2+3 | 2=5+8 | 3=6+9 | 4=5+6 | 5 | 6 | 7=8+9 | 8 | 9 |
| I | សរុបរួម | | | | | | | | | |
| 1 | គាំទ្រកិច្ចដំណើរការ | | | | | | | | | |
| 1.1 | កិច្ចដំណើរការរដ្ឋបាល | | | | | | | | | |
| 1.2 | ការថែទាំនិងជួសជុលផ្សេងៗ | | | | | | | | | |
| 2 | កែលម្អគុណភាពអប់រំ | | | | | | | | | |
| 2.1 | ការចូលរៀនដោយសមធម៌និងបង្ការសិស្សបោះបង់ | | | | | | | | | |
| 2.2 | សម្ភារៈរៀននិងបង្រៀន | | | | | | | | | |
| 2.3 | ការកែលម្អបរិស្ថាននិងទីធ្លាកំសាន្ត | | | | | | | | | |
| 2.4 | ការអប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | | | | |
| II | ថវិការដ្ឋ | | | | | | | | | |
| 1 | គាំទ្រកិច្ចដំណើរការ | | | | | | | | | |
| 1.1 | កិច្ចដំណើរការរដ្ឋបាល | | | | | | | | | |
| 1.2 | ការថែទាំនិងជួសជុលផ្សេងៗ | | | | | | | | | |
| 2 | កែលម្អគុណភាពអប់រំ | | | | | | | | | |
| 2.1 | ការចូលរៀនដោយសមធម៌និងបង្ការសិស្សបោះបង់ | | | | | | | | | |
| 2.2 | សម្ភារៈរៀននិងបង្រៀន | | | | | | | | | |
| 2.3 | ការកែលម្អបរិស្ថាននិងទីធ្លាកំសាន្ត | | | | | | | | | |
| 2.4 | ការអប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | | | | |
| III | ថវិកាដៃគូ | | | | | | | | | |
| 1 | គាំទ្រកិច្ចដំណើរការ | | | | | | | | | |
| 1.1 | កិច្ចដំណើរការរដ្ឋបាល | | | | | | | | | |
| 1.2 | ការថែទាំនិងជួសជុលផ្សេងៗ | | | | | | | | | |
| 2 | កែលម្អគុណភាពអប់រំ | | | | | | | | | |
| 2.1 | ការចូលរៀនដោយសមធម៌និងបង្ការសិស្សបោះបង់ | | | | | | | | | |
| 2.2 | សម្ភារៈរៀននិងបង្រៀន | | | | | | | | | |
| 2.3 | ការកែលម្អបរិស្ថាននិងទីធ្លាកំសាន្ត | | | | | | | | | |
| 2.4 | ការអប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | | | | |

| ល.រ | បរិយាយ | សរុប | | | កម្រិត... | | | កម្រិត... | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | លើកទី១ | លើកទី២ | សរុប | លើកទី១ | លើកទី២ | សរុប | លើកទី១ | លើកទី២ |
| III.1 | **ថវិកាដៃគូ.....** | | | | | | | | | |
| 1 | **គាំទ្រកិច្ចដំណើរការ** | | | | | | | | | |
| 1.1 | កិច្ចដំណើរការរដ្ឋបាល | | | | | | | | | |
| 1.2 | ការថែទាំនិងជួសជុលផ្សេងៗ | | | | | | | | | |
| 2 | **កែលម្អគុណភាពអប់រំ** | | | | | | | | | |
| 2.1 | ការចូលរៀនដោយសមធម៌និងបង្ការសិស្សបោះបង់ | | | | | | | | | |
| 2.2 | សម្ភារៈរៀននិងបង្រៀន | | | | | | | | | |
| 2.3 | ការកែលម្អបរិស្ថាននិងទីធ្លាកំសាន្ត | | | | | | | | | |
| 2.4 | ការអប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | | | | |
| III.2 | **ថវិកាដៃគូ.....** | | | | | | | | | |
| | ........ | | | | | | | | | |
| IV | **ថវិកាសហគមន៍** | | | | | | | | | |
| 1 | **គាំទ្រកិច្ចដំណើរការ** | | | | | | | | | |
| 1.1 | កិច្ចដំណើរការរដ្ឋបាល | | | | | | | | | |
| 1.2 | ការថែទាំនិងជួសជុលផ្សេងៗ | | | | | | | | | |
| 2 | **កែលម្អគុណភាពអប់រំ** | | | | | | | | | |
| 2.1 | ការចូលរៀនដោយសមធម៌និងបង្ការសិស្សបោះបង់ | | | | | | | | | |
| 2.2 | សម្ភារៈរៀននិងបង្រៀន | | | | | | | | | |
| 2.3 | ការកែលម្អបរិស្ថាននិងទីធ្លាកំសាន្ត | | | | | | | | | |
| 2.4 | ការអប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | | | | |
| V | **ថវិកាផ្សេងៗ** | | | | | | | | | |
| 1 | **គាំទ្រកិច្ចដំណើរការ** | | | | | | | | | |
| 1.1 | កិច្ចដំណើរការរដ្ឋបាល | | | | | | | | | |
| 1.2 | ការថែទាំនិងជួសជុលផ្សេងៗ | | | | | | | | | |
| 2 | **កែលម្អគុណភាពអប់រំ** | | | | | | | | | |
| 2.1 | ការចូលរៀនដោយសមធម៌និងបង្ការសិស្សបោះបង់ | | | | | | | | | |
| 2.2 | សម្ភារៈរៀននិងបង្រៀន | | | | | | | | | |
| 2.3 | ការកែលម្អបរិស្ថាននិងទីធ្លាកំសាន្ត | | | | | | | | | |
| 2.4 | ការអប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ | | | | | | | | | |

ថ្ងៃ.................. ខែ........ ឆ្នាំ........... ព.ស...

ធ្វើនៅ........ ថ្ងៃទី........ ខែ........ឆ្នាំ....

**ហេរញ្ញិក**

**បានឃើញនិងឯកភាព**

**ប្រធានគ.ម.ស**

**ឧបសម្ព័ន្ធភ្ជាប់លិខិតលេខ ១១ អយក.សណាចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ២០២៦**
**ស្ដីពី ទម្រង់គំរូសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ**

**ឧបសម្ព័ន្ធទី៣៖ ទម្រង់គំរូផែនការប្រតិបត្តិប្រចាំឆ្នាំ**

## ១. សេចក្ដីផ្ដើម

សេចក្ដីផ្ដើម ត្រូវមានភាពទាក់ទាញធ្វើឱ្យអ្នកអានមានចំណាប់អារម្មណ៍ចូលរួមចំណែកក្នុងការអភិវឌ្ឍសាលារៀន និងត្រូវបង្ហាញពីគោលបំណង និងទិសដៅរួមរបស់សាលារៀនសម្រាប់ឆ្នាំថ្មី។ សាលារៀនត្រូវគូសបញ្ជាក់ពីការប្រែក្លាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន៥ឆ្នាំ ទៅជាសកម្មភាពជាក់ស្ដែងប្រចាំឆ្នាំ ដើម្បីឆ្លើយតបទៅនឹងទិសដៅអាទិភាពកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា។ ជារួម សាលារៀនត្រូវសរសេរផ្នែកនៃសេចក្ដីផ្ដើម ឱ្យគ្របដណ្ដប់លើចំណុចគន្លឹះៗដូចខាងក្រោម៖

- ការរៀបរាប់បរិបទ និងស្ថានភាពបច្ចុប្បន្ន(តួនាទី និងភារកិច្ចរបស់សាលារៀនក្នុងប្រព័ន្ធអប់រំជាតិ ស្ថានភាពបច្ចុប្បន្នរបស់សាលារៀនដូចជា៖ សមត្ថភាពគ្រូបង្រៀន និងបុគ្គលិក ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈ បញ្ហាប្រឈម និងឱកាសសំខាន់ៗជាដើម ដែលជាមូលដ្ឋានសម្រាប់ការធ្វើផែនការ)
- បង្ហាញពីមូលហេតុក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ផ្ដោតលើទិដ្ឋភាពទូទៅ និងអាទិភាពសម្រាប់ឆ្នាំអនុវត្ត ព្រមទាំងទិសដៅ ដើម្បីដោះស្រាយបញ្ហាប្រឈម និងលើកកម្ពស់គុណភាពអប់រំ ដោយត្រូវផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងអាទិភាពកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា
- ការចូលរួមពីភាគីពាក់ព័ន្ធ និងការប្ដេជ្ញាចិត្ត
- វិសាលភាព និងក្របខណ្ឌពេលវេលា

## ២. ចំណុចខ្លាំង និងបញ្ហាប្រឈម

### ២.១ ចំណុចខ្លាំង

ក្នុងឆ្នាំសិក្សា........ សាលារៀនសម្រេចបានសូចនាករគន្លឹះ/គោលសំខាន់ៗ ដែលមានវឌ្ឍនភាពល្អប្រសើរ ដូចខាងក្រោម៖

#### ២.១.១ លទ្ធផលសិក្សារបស់សិស្ស

- បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី១ ស្ដីពីលទ្ធផលសិក្សារបស់សិស្ស សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

#### ២.១.២ ការបង្រៀននិងរៀន

- បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី២ ស្ដីពីការបង្រៀននិងរៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង

• វិភាគ និងពន្យល់លើលទ្ធផល

### ២.១.៣ ការចូលរួមរបស់សហគមន៍

• បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៣ ស្តីពីការចូលរួមរបស់សហគមន៍ សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ

• រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង

• វិភាគ និងពន្យល់លើលទ្ធផល

### ២.១.៤ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន

• បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៤ ស្តីពីដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ

• រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង

• វិភាគ និងពន្យល់លើលទ្ធផល

### ២.១.៥ គណនេយ្យភាពរបស់សាលារៀន

• បរិយាយអំពីវឌ្ឍនភាពនៃសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៥ ស្តីពីគណនេយ្យភាពរបស់សាលារៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានវឌ្ឍនភាពល្អប្រសើរ

• រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង

• វិភាគ និងពន្យល់លើលទ្ធផល

## ២.២ បញ្ហាប្រឈម

ទោះបីជាសាលារៀនមានវឌ្ឍនភាពដូចបានរៀបរាប់ខាងលើ ក៏សាលារៀនមានបញ្ហាប្រឈមមិនអាចសម្រេចបានសូចនាករគន្លឹះ/គោលសំខាន់ៗ ដូចខាងក្រោម៖

### ២.២.១ លទ្ធផលសិក្សារបស់សិស្ស

• បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី១ ស្តីពីលទ្ធផលសិក្សារបស់សិស្ស សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម

• រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង

• វិភាគ និងពន្យល់លើលទ្ធផល

### ២.២.២ ការបង្រៀននិងរៀន

• បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី២ ស្តីពីការបង្រៀននិងរៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម

• រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង

• វិភាគ និងពន្យល់លើលទ្ធផល

### ២.២.៣ ការចូលរួមរបស់សហគមន៍

- បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៣ ស្តីពីការចូលរួមរបស់សហគមន៍ សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

### ២.២.៤ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន

- បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៤ ស្តីពីដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

### ២.២.៥ គណនេយ្យភាពរបស់សាលារៀន

- បរិយាយអំពីបញ្ហាប្រឈមដែលមិនអាចសម្រេចបាននូវសូចនាករក្នុងឆ្នាំ(N) ធៀបនឹងគោលដៅឆ្នាំ(N) ដែលសាលារៀនបានកំណត់ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំកន្លងទៅ ឆ្លើយតបស្តង់ដាសាលារៀនគំរូ ក្នុងស្តង់ដាទី៥ ស្តីពីគណនេយ្យភាពរបស់សាលារៀន សម្រាប់សូចនាករគន្លឹះ/គោល ដែលមានបញ្ហាប្រឈម
- រៀបចំបង្ហាញជាក្រាហ្វ ដ្យាក្រាម ឬតារាង
- វិភាគ និងពន្យល់លើលទ្ធផល

## ៣. គោលបំណង

សូមសរសេរអំពីគោលបំណងនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ដើម្បីរៀបចំផែនការសកម្មភាពគាំទ្រការផ្តល់សេវា និងលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែល្អប្រសើរឡើង និងដំណោះស្រាយបញ្ហាប្រឈម។

## ៤. សូចនាករសមិទ្ធកម្ម និងគោលដៅ

| ស្តង់ដា និងសូចនាករ | ឯកតា | លទ្ធផលសូចនាករឆ្នាំបច្ចុប្បន្ន (N) | គោលដៅសូចនាករឆ្នាំគ្រោងថវិកា (N+1) | ឆ្នាំគ្រោងថវិកា(N+1) | | |
|---|---|---|---|---|---|---|
| | | | | ថវិការដ្ឋ | ក្រៅពីថវិការដ្ឋ | ថវិកាសរុប |
| **ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស** | | | | | | |
| ១. ការប្រមូលកុមារចូលរៀន | | | | | | |
| ១.១ ...................................... | | | | | | |
| ............................................. | | | | | | |
| **ស្តង់ដាទី២៖ ការបង្រៀននិងរៀន** | | | | | | |
| ១. ការអនុវត្តវិធីសាស្ត្របង្រៀន | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១.១ ........................................ | | | | | | |
| ................................................ | | | | | | |
| **ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍** | | | | | | |
| ១. ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និង ថ្នាក់រៀន... | | | | | | |
| ១.១ ........................................ | | | | | | |
| ................................................ | | | | | | |
| **ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន** | | | | | | |
| ១. ការគ្រប់គ្រងរដ្ឋបាលទូទៅ | | | | | | |
| ១.១ ........................................ | | | | | | |
| ................................................ | | | | | | |
| **ស្តង់ដាទី៥៖ គណនេយ្យភាព** | | | | | | |
| ១. វេទិកាសាធារណៈ | | | | | | |
| ១.១ ........................................ | | | | | | |
| ................................................ | | | | | | |

## ៥. សកម្មភាពអនុវត្ត

សាលារៀន ត្រូវកត់សម្គាល់លើចំណុចសំខាន់ៗ ដែលត្រូវបំពេញក្នុងតារាងដូចខាងក្រោម៖

- សូមលើកពីសកម្មភាពដែលត្រូវអនុវត្ត និងគាំទ្រ នាំឱ្យសម្រេចគោលដៅសូចនាករ (សូចនាករមួយ អាចគាំទ្រដោយសកម្មភាពមួយ ឬច្រើន)
- សូមសរសេរអំពីលទ្ធផលគ្រោងទុកដែលកើតចេញពីសកម្មភាពនីមួយៗ (សកម្មភាពមួយ មានលទ្ធផលគ្រោងទុកមួយ) ក្នុងន័យនេះ លទ្ធផលគ្រោងទុកមិនមែនជាឈ្មោះសូចនាករទេ
- ការកំណត់ "ឯកតា" គឺផ្អែកទៅលើលទ្ធផលគ្រោងទុកដែលបានលើកឡើង

| លទ្ធផលគ្រោងទុក | សកម្មភាព | ឯកតា | លទ្ធផលតាមក្របខ័ណ្ឌពេលវេលា | | | | អ្នកទទួលខុសត្រូវ | ប្រភពធនធាន | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ត្រី១ | ត្រី២ | ត្រី៣ | ត្រី៤ | | សរុបរួម | ថវិការដ្ឋ | ក្រៅពីថវិការដ្ឋ | | | |
| | | | | | | | | | | សរុប | ដៃគូ | សហគមន៍ | ថវិកាផ្សេងៗ |
| រូបមន្ត | | | | | | | | 1=2+3 | 2 | 3=4+5+6 | 4 | 5 | 6 |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | | | | | | | | | | |
| ១. ការប្រមូលកុមារចូលរៀន | | | | | | | | | | | | | |
| .. ......... | ........... | | | | | | | | | | | | |
| ........... | ........... | | | | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ស្តង់ដាទី២៖** ការបង្រៀននិងរៀន | | | | | | | | | | | | | |
| ១. ការអនុវត្តវិធីសាស្ត្របង្រៀន | | | | | | | | | | | | | |
| .......... | .......... | | | | | | | | | | | | |
| .. .......... | .......... | | | | | | | | | | | | |
| **ស្តង់ដាទី៣៖** ការចូលរួមរបស់សហគមន៍ | | | | | | | | | | | | | |
| ១. ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងថ្នាក់រៀន | | | | | | | | | | | | | |
| .......... | .......... | | | | | | | | | | | | |
| .. .......... | .. .......... | | | | | | | | | | | | |
| **ស្តង់ដាទី៤៖** ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន | | | | | | | | | | | | | |
| ១. ការគ្រប់គ្រងរដ្ឋបាលទូទៅ | | | | | | | | | | | | | |
| .......... | .......... | | | | | | | | | | | | |
| .. .......... | .. .......... | | | | | | | | | | | | |
| **ស្តង់ដាទី៥៖** គណនេយ្យភាពរបស់សាលារៀន | | | | | | | | | | | | | |
| ១. វេទិកាសាធារណៈ | | | | | | | | | | | | | |
| .......... | .......... | | | | | | | | | | | | |
| .. .......... | .......... | | | | | | | | | | | | |

## ៦. សេចក្តីសន្និដ្ឋាន

ជាការសន្និដ្ឋានរួម ដោយធ្វើការបូកសរុបសង្ខេបអំពីសារៈសំខាន់នៃផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានរៀបចំ ព្រម ជាមួយនឹងការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានដាក់ចេញ។

ថ្ងៃ.............................. ខែ...................ឆ្នាំ................ព.ស........

................................ ថ្ងៃទី........ខែ................ឆ្នាំ...............

**ប្រធានគ.ម.ស**

**បានពិនិត្យត្រឹមត្រូវ**

**ប្រធានគ.គ.ស**

**បានពិនិត្យត្រឹមត្រូវ**

**ប្រធានការិយាល័យអប់រំ យុវជន និងកីឡា**

**បានឃើញនិងឯកភាព**

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡា**

**ឬ**

**អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**

**សម្គាល់៖**

១) គ្រឹះស្ថានសិក្សាសាធារណៈស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវអនុម័ត(បានឃើញនិងឯកភាព)ដោយលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

២) គ្រឹះស្ថានសិក្សាសាធារណៈត្រូវបានផ្ទេរទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុម័ត(បានឃើញនិងឯកភាព)ដោយលោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**ឧបសម្ព័ន្ធភ្ជាប់លិខិតលេខ ១១ អយក.សណាន ចុះថ្ងៃទី១០ ខែ មីនា ឆ្នាំ២០២៦**

**ស្តីពី ទម្រង់គំរូសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ**

**ឧបសម្ព័ន្ធទី៤៖ ទម្រង់គំរូកិច្ចបញ្ជីកាគណនេយ្យនិងរបាយការណ៍សម្រាប់សាលារៀនស្ថិតក្រោមគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡា**

**ឧបសម្ព័ន្ធទី៤.១**

**ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ...**

ឈ្មោះសាលារៀន....

*ទម្រង់គំរូលេខ ១*

**បណ្ណចំណូល**

ថ្ងៃទី.........ខែ.........ឆ្នាំ២០... លេខ............

ឥណពន្ធ :

ឥណទាន :

ប្រភពថវិកា

រដ្ឋ : ៛................................

ដៃគូ : ៛................................

សហគមន៍ : ៛................................

ផ្សេងៗ : ៛................................

ទទួលពី.................................................. មុខងារ ...................................................................................

ចំនួនទឹកប្រាក់ជាអក្សរ.............................................................................................................................

អត្ថន័យចំណូល.......................................................................................................................................

ភ្ជាប់ជាមួយសក្ខីបត្រដើម.........................................................................................................................

| ប្រធានអង្គភាព | អ្នកពិនិត្យ | បេឡាធិការ |
|---|---|---|
| | | |
| ឈ្មោះ................................. | ឈ្មោះ................................. | ឈ្មោះ............................. |
| ប្រធានគ.ម.ស | អនុប្រធានគ.ម.ស | ហេរញ្ញិក |

ឧបសម្ព័ន្ធទី៤.២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ទម្រង់គំរូលេខ ២ក

**ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ**........
**ឈ្មោះសាលារៀន**.........................

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................................ជា ................................................

**សូមគោរពជូន**

លោកនាយក/លោកស្រីនាយិកា..........................

កម្មវត្ថុ៖ សំណើសុំថវិកាចំនួន............................... (សរសេរទឹកប្រាក់ជាអក្សរ) សម្រាប់.......................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមលោក/លោកស្រី ..................................មេត្តាពិនិត្យលទ្ធភាពអនុញ្ញាផ្តល់ថវិកាចំនួន..................សម្រាប់...............................ក្នុងអនុគណនី......................សកម្មភាពគោលទី............សកម្មភាពរងទី.....................ដើម្បី............................ដោយអនុគ្រោះ។

សូមលោក/លោកស្រី............................... ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ថ្ងៃ.................. ខែ........ ឆ្នាំ............ ព.ស...........

..................ថ្ងៃទី.........ខែ........ឆ្នាំ........

អ្នកស្នើសុំ

ឧបសម្ព័ន្ធទី៤.៣

**ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ....**

**ឈ្មោះសាលារៀន....** *ទម្រង់គំរូលេខ ៣*

**បណ្ណចំណាយ**

ថ្ងៃទី.........ខែ..........ឆ្នាំ២០... លេខ............

ឥណពន្ធ :

ឥណទាន :

ប្រភពថវិកា

រដ្ឋ : រ៛.................................

ដៃគូ : រ៛.................................

សហគមន៍ : រ៛.................................

ផ្សេងៗ : រ៛.................................

បើកជូនលោក/លោកស្រី.........................................មុខងារ...................................................

ចំនួនទឹកប្រាក់ជាអក្សរ..........................................................................................................

អត្ថន័យចំណាយ....................................................................................................................

ខ្ទង់ចំណាយ...........................................................................................................................

ភ្ជាប់ជាមួយសក្ខីបត្រដើម......................................................................................................

| ប្រធានអង្គភាព | អ្នកពិនិត្យ | អ្នកប្រគល់ប្រាក់ | អ្នកទទួលប្រាក់ |
|---|---|---|---|
| | | | |
| ឈ្មោះ........................... | ឈ្មោះ......................... | ឈ្មោះ....................... | ឈ្មោះ................... |
| ប្រធានគ.ម.ស | អនុប្រធានគ.ម.ស | ហេរញ្ញិក | អ្នកស្នើសុំ |

# ឧបសម្ព័ន្ធទី៤.៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ...** *ទម្រង់គំរូលេខ ៤*

**ឈ្មោះសាលារៀន....**

## បញ្ជីតាមដានប្រាក់នៅធនាគារ

ប្រចាំខែ..... ឆ្នាំ........

ឯកតា៖ រៀល

| ល.រ | សក្ខីបត្រ | | | បរិយាយ | ប្រភពថវិកា | សាច់ប្រាក់នៅធនាគារ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រភេទ | លេខ | ថ្ងៃខែឆ្នាំ | | | សមតុល្យដើមគ្រា | សរុបក្នុងខែនេះ | | សរុបបណ្ដាខែមុន | | សរុបយោងពីដើមគ្រាដល់ចុងខែនេះ | | |
| | | | | | | | ដាក់សាច់ប្រាក់ | ដកសាច់ប្រាក់ | ដាក់សាច់ប្រាក់ | ដកសាច់ប្រាក់ | ដាក់សាច់ប្រាក់ | ដកសាច់ប្រាក់ | សមតុល្យ |
| | | | | រូបមន្ត | | 1 | 2 | 3 | 4 | 5 | 6=1+2+4 | 7=3+5 | 8=6-7 |
| | | | | សរុប | | | | | | | | | |
| | | | | ថវិការដ្ឋ | 1 | | | | | | | | |
| | | | | ថវិកាដៃគូ | 2 | | | | | | | | |
| | | | | 1. ..... | 2.1 | | | | | | | | |
| | | | | ....... | .... | | | | | | | | |
| | | | | ថវិកាសហគមន៍ | 3 | | | | | | | | |
| | | | | ថវិកាផ្សេងៗ | 4 | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

បានបញ្ឈប់បញ្ជីត្រឹមថ្ងៃទី ខែ ឆ្នាំ ដោយមានទឹកប្រាក់នៅសល់ចំនួន (សរសេរជាអក្សរ).......................................................................។

តារាងផ្ទៀងផ្ទាត់ជាមួយសមតុល្យសាច់ប្រាក់ប្រចាំខែ
១.សមតុល្យក្នុងបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារប្រចាំខែ៖
២.សមតុល្យក្នុងរបាយការណ៍ធនាគារប្រចាំខែ៖
៣.លម្អៀង៖
៤.មូលហេតុ៖

ថ្ងៃ.................. ខែ........ ឆ្នាំ........... ព.ស...

ធ្វើនៅ........ ថ្ងៃទី........ ខែ........ឆ្នាំ....

**បានឃើញនិងឯកភាព**
**ប្រធានគ.ម.ស**

**ហេរញ្ញិក**

## ឧបសម្ព័ន្ធទី៤.៥

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ...** *ទម្រង់គំរូលេខ ៥*

**ឈ្មោះសាលារៀន....**

### បញ្ជីបេឡា
ប្រចាំខែ.......ឆ្នាំ........

ឯកតា៖ រៀល

| ល.រ | សក្ខីបត្រ | | បរិយាយ | ប្រភពថវិកា | សាច់ប្រាក់ក្នុងបេឡា | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លេខ | ថ្ងៃខែឆ្នាំ | | | សមតុល្យដើមគ្រា | សរុបក្នុងខែនេះ | | សរុបបណ្ដាខែមុន | | សរុបយោងពីដើមគ្រាដល់ចុងខែនេះ | | |
